គណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេស
**COMMITTEE FOR ELECTION RIGHTS OF OVERSEAS CAMBODIANS (THE CEROC)**
**Email:** board@khmeroversea.info, www.khmeroversea.info

# សេចក្តីថ្លែងការណ៍

អំពីព្រឹទ្ធសភាឯកបក្សឆ្នាំ២០១៨-២០២៣

**សូមគោរពបងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា!**

គណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេសមានការខកចិត្តជាខ្លាំងដែលព្រឹទ្ធសភាថ្មីប្រចាំអណត្តិ២០១៨-២០១៣និងដែលបានយាងអធិបតីប្រកាសសុពលភាពដោយព្រះមហាក្សត្រ គឺជាព្រឹទ្ធសភាឯកបក្សផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញត្រង់មាត្រា៥១ថ្មីដែលមានចែងយ៉ាងច្បាស់ថា ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស...។

អង្គការសហប្រជាជាតិបានចំណាយធនធានរាប់កោដិលានដុល្លាដើម្បីកសាងនិងពង្រឹងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ប៉ុន្តែរបបលោកហ៊ុន-សែន មិនមែនមិនបានពង្រីកនិងពង្រឹងប៉ុណ្ណោះទេថែមទាំងបំផ្លាញចោលទាំងស្រុងតែម្តងដោយប្លន់យកឆន្ទៈរាស្ត្រដែលបោះឆ្នោតអោយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ទាំង៥០០៧នាក់ពីគណបក្សសង្គ្រោះជាតិដើម្បីបង្កើតព្រឹទ្ធសភាបែបផ្តាច់ការតែម្តង។

យើងត្រូវការការបោះឆ្នោតមួយដែលមានន័យពិតប្រាកដ ដែលយើងអាចទទួលយកបានទាំងអស់គ្នា។ ការរំលាយគណបក្សសង្គ្រោះជាតិ ការយកកៅអីសភានិងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់របស់គណបក្សសង្គ្រោះជាតិទៅចែកអោយបក្សផ្សេង គឺស្មើនឹងការជាន់ឈ្លីប្រជាពលរដ្ឋអ្នកបោះឆ្នោតជិតកន្លះប្រទេស ជាការរំលោភលើរដ្ឋធម្មនុញ្ញកម្ពុជា និងជាការរំលោភលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស២៣ តុលា ឆ្នាំ១៩៩១។ ការបោះឆ្នោតព្រឹទ្ធិសភាកាលថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ដោយគ្មានគណបក្សសង្គ្រោះជាតិចូលរួមគឺជាការបោះឆ្នោតបង្គ្រប់កិច្ចរបស់លទ្ធិផ្តាច់ការឯកបក្សតែប៉ុណ្ណោះ។

ជាការកត់សំគាល់មួយទៀត តំណែងព្រឹទ្ធសភាមួយចំនួនធំគឺជាឧញ៉ាដែលជាម្ចាស់ជំនួញធំៗក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រការនេះគឺផ្ទុយទៅនឹងស្មារតីច្បាប់ដែលហាមបុគ្គលទាំងឡាយនេះមិនអោយកាន់កាប់តំណែងរដ្ឋាភិបាលព្រោះអាចនាំផលវិបាកក្នុងរឿងប៉ះពាល់ដល់ទំនាស់ផលប្រយោជន៍គឺការញែកមិនដាច់រវាងផលប្រយោជន៍ជាតិនិងផលប្រយោជន៍ផ្ទាល់ខ្លួនតែម្តង។

យើងខ្ញុំដែលជាប្រជាពលរដ្ឋខ្មែររស់ឯនៅនាយសមុទ្រទាំងអស់ដែលមានចំនួនដល់ទៅ៣លាន

នាក់ នៅតែទាមទារអោយមានការអនុវត្តន៍តាមរដ្ឋធម្មនុញ្ញខ្មែរអោយបានត្រឹមត្រូវដើម្បីធានានូវនិរន្តរភាពនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជាអោយបានពិតប្រាកដ។ ក្នុងកាលៈទេសៈបច្ចុប្បន្ន ក្រោមការដឹកនាំរបស់លោកហ៊ុន-សែននិងគណបក្សប្រជាជន ហើយបើការបោះឆ្នោតជាតិខាងមុខមិនមានការចូលរួមពីគណបក្សសង្គ្រោះជាតិទេប្រទេសកម្ពុជានិងប្រជាពលរដ្ឋកម្ពុជាអាចនឹងជួបគ្រោះហ៍ភ័យដូចក្នុងកំឡុងខ្មែរក្រហមឡើងកាន់កាប់អំណាចក្នុងឆ្នាំ១៩៧៥ ដូច្នោះដែរ។

*ជយោ លទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋនៅកម្ពុជា!*

*ជយោ ស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសអមតៈ!*

*ជយោ កំឡាំងសាមគ្គីរបស់ប្រជាពលរដ្ឋខ្មែរនៅក្រៅប្រទេស-ក្នុងប្រទេសទាំងអស់!*

ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន
លេខ..៤៤៦../០៤.១៨/អ.គស/ជរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា៖ នៅព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ វេលាម៉ោង ៩:០០នាទីព្រឹក ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានប្រារព្ធការបើកសម័យប្រជុំដំបូង នីតិកាលទី៤ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

បន្ទាប់ពីពិធីបើកជាផ្លូវការ អង្គព្រឹទ្ធសភា បានដំណើរការក្រោមការដឹកនាំរបស់ឯកឧត្តម **ម៉ុម ឌឹមហ្មុយ** ប្រធានបណ្តោះអាសន្នព្រឹទ្ធសភានីតិកាលទី៤។

**អង្គប្រជុំព្រឹទ្ធសភាបាន៖**

**១-ប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកព្រឹទ្ធសភាទាំង ៦២រូប គឺ៖**

| | |
|---|---|
| ១.ឯកឧត្តម **សៀយ គៀច** | គណបក្សប្រជាជនកម្ពុជា |
| ២.ឯកឧត្តម **ម៉ុម ឌឹមហ៊ុយ** | គណបក្សប្រជាជនកម្ពុជា |
| ៣.លោកជំទាវ **ទី បូរ៉ាស៊ី** | គណបក្សប្រជាជនកម្ពុជា |
| ៤.ឯកឧត្តម **ផុង ចន់** | គណបក្សប្រជាជនកម្ពុជា |
| ៥.ឯកឧត្តម **អ៊ុក ប៊ុនឈឿន** | គណបក្សប្រជាជនកម្ពុជា |
| ៦.ឯកឧត្តម **សួន លន់** | គណបក្សប្រជាជនកម្ពុជា |
| ៧.ឯកឧត្តម **យ៉ង់ សែម** | គណបក្សប្រជាជនកម្ពុជា |
| ៨.ឯកឧត្តម **ឡាច ម៉េងឃីន** | គណបក្សប្រជាជនកម្ពុជា |
| ៩.ឯកឧត្តម **សុខ យាត** | គណបក្សប្រជាជនកម្ពុជា |
| ១០.សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** | គណបក្សប្រជាជនកម្ពុជា |
| ១១.ឯកឧត្តម **សុខ ឥសាន** | គណបក្សប្រជាជនកម្ពុជា |



វិមានវឌ្ឍនការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| ១២.ឯកឧត្តម **ធេព ខន** | គណបក្សប្រជាជនកម្ពុជា |
| ១៣.ឯកឧត្តម **ចាន់ ណារ៉េត** | គណបក្សប្រជាជនកម្ពុជា |
| ១៤.ឯកឧត្តម **ណាំ ទុំ** | គណបក្សប្រជាជនកម្ពុជា |
| ១៥.ឯកឧត្តម **ឈិត គីមយាត** | គណបក្សប្រជាជនកម្ពុជា |
| ១៦.ឯកឧត្តម **គង់ សារាជ** | គណបក្សប្រជាជនកម្ពុជា |
| ១៧.ឯកឧត្តម **ឡាយ អ៊ីពិសិទ្ធិ** | គណបក្សប្រជាជនកម្ពុជា |
| ១៨.ឯកឧត្តម **ជា ចេដ្ឋ** | គណបក្សប្រជាជនកម្ពុជា |
| ១៩.ឯកឧត្តម **ស៊ីម ការ** | គណបក្សប្រជាជនកម្ពុជា |
| ២០.ឯកឧត្តម **នៃ ប៉េណា** | គណបក្សប្រជាជនកម្ពុជា |
| ២១.ឯកឧត្តម **គិន ណែត** | គណបក្សប្រជាជនកម្ពុជា |
| ២២.ឯកឧត្តម **អ៊ុក គង់** | គណបក្សប្រជាជនកម្ពុជា |
| ២៣.លោកជំទាវ **ស៊ុខ ស៊ីយុត** | គណបក្សប្រជាជនកម្ពុជា |
| ២៤.ឯកឧត្តម **ប៉ុល លឹម** | គណបក្សប្រជាជនកម្ពុជា |
| ២៥.ឯកឧត្តម **ម៉ាន់ ឈឿន** | គណបក្សប្រជាជនកម្ពុជា |
| ២៦.លោកជំទាវ **អ៊ី សុម៉ានីន** | ចាត់តាំងដោយព្រះមហាក្សត្រ |
| ២៧.ឯកឧត្តម **អន ស៊ី** | គណបក្សប្រជាជនកម្ពុជា |
| ២៨.ឯកឧត្តម **ហែម ខន** | គណបក្សប្រជាជនកម្ពុជា |
| ២៩.ឯកឧត្តម **ច្រឹង គីមស្រ៊ាន** | គណបក្សប្រជាជនកម្ពុជា |
| ៣០.ឯកឧត្តម **ខៀវ មុត** | គណបក្សប្រជាជនកម្ពុជា |
| ៣១.ឯកឧត្តម **មួង ប៉ុយ** | គណបក្សប្រជាជនកម្ពុជា |
| ៣២.ឯកឧត្តម **ទឹម ផន** | គណបក្សប្រជាជនកម្ពុជា |
| ៣៣.ឯកឧត្តម **ជុំ ទង** | គណបក្សប្រជាជនកម្ពុជា |
| ៣៤.ឯកឧត្តម **ឡាន់ ឆន** | គណបក្សប្រជាជនកម្ពុជា |
| ៣៥.ឯកឧត្តម **ឈួន ឡេង** | គណបក្សប្រជាជនកម្ពុជា |
| ៣៦.លោកជំទាវ **មុំ សណ្ដាប់** | គណបក្សប្រជាជនកម្ពុជា |
| ៣៧.ឯកឧត្តម **ម៉ែន ស៊ីផាន់** | គណបក្សប្រជាជនកម្ពុជា |

| | |
|---|---|
| ៣៨.លោកជំទាវ **ឱ សុខុម** | គណបក្សប្រជាជនកម្ពុជា |
| ៣៩.ឯកឧត្តម **អុក អេន** | គណបក្សប្រជាជនកម្ពុជា |
| ៤០.ឯកឧត្តម **ម៉ុង ឫទ្ធី** | គណបក្សប្រជាជនកម្ពុជា |
| ៤១.ឯកឧត្តម **ប្រាក់ ចំរើន** | គណបក្សប្រជាជនកម្ពុជា |
| ៤២.ឯកឧត្តម **ញ៉ែម សាម៉ន** | គណបក្សប្រជាជនកម្ពុជា |
| ៤៣.លោកជំទាវ **ឯម ផលាមុនី** | គណបក្សប្រជាជនកម្ពុជា |
| ៤៤.ឯកឧត្តម **តឹម ឆា** | គណបក្សប្រជាជនកម្ពុជា |
| ៤៥.ឯកឧត្តម **សាយ បូរិន** | គណបក្សប្រជាជនកម្ពុជា |
| ៤៦.ឯកឧត្តម **ស្រី បេន** | គណបក្សប្រជាជនកម្ពុជា |
| ៤៧.សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** | ចាត់តាំងដោយព្រះមហាក្សត្រ |
| ៤៨.លោកជំទាវ **មាន សំអាន** | គណបក្សប្រជាជនកម្ពុជា |
| ៤៩.ឯកឧត្តម **អោយ ខន** | គណបក្សប្រជាជនកម្ពុជា |
| ៥០.ឯកឧត្តម **ម៉ម ប៊ុននាង** | គណបក្សប្រជាជនកម្ពុជា |
| ៥១.ឯកឧត្តម **សត ណាឌី** | គណបក្សប្រជាជនកម្ពុជា |
| ៥២.លោកជំទាវ **ស៊ី ចណ្ណថា** | គណបក្សប្រជាជនកម្ពុជា |
| ៥៣.ឯកឧត្តម **ជឹម លាច** | គណបក្សប្រជាជនកម្ពុជា |
| ៥៤.ឯកឧត្តម **លី យ៉ុងផាត់** | គណបក្សប្រជាជនកម្ពុជា |
| ៥៥.ឯកឧត្តម **ទេព យុទ្ធី** | គណបក្សប្រជាជនកម្ពុជា |
| ៥៦.ឯកឧត្តម **ឈើយ ចាន់ណា** | គណបក្សប្រជាជនកម្ពុជា |
| ៥៧.ឯកឧត្តម **លី សារី** | គណបក្សប្រជាជនកម្ពុជា |
| ៥៨.ឯកឧត្តម **សូន មាន** | ជ្រើសតាំងដោយរដ្ឋសភា |
| ៥៩.ឯកឧត្តម **ឆាយ ចណ្ណា** | គណបក្សប្រជាជនកម្ពុជា |
| ៦០.លោកជំទាវ **ឃួន ឃុនឌី** | គណបក្សប្រជាជនកម្ពុជា |
| ៦១.ឯកឧត្តម **ហេង បូរ៉ា** | គណបក្សប្រជាជនកម្ពុជា |
| ៦២.លោកជំទាវ **ជា ច័ន្ទទេវី** | ជ្រើសតាំងដោយរដ្ឋសភា។ |

**២-បោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ព្រឹទ្ធសភា**

ព្រឹទ្ធសភា បានបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន និងអនុប្រធាន ២រូប នៃព្រឹទ្ធសភា នីតិកាលទី៤ ដោយទទួលបានលទ្ធផលដូចតទៅ៖

១-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ជាប្រធានព្រឹទ្ធសភា ដោយមានសំឡេងគាំទ្រ ចំនួន ៦២សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

២-ឯកឧត្តម **នៃ ប៉េណា** ជាអនុប្រធានទី១ព្រឹទ្ធសភា ដោយមានសំឡេងគាំទ្រ ចំនួន ៦២សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

៣-ឯកឧត្តម **ឆេត ខន** ជាអនុប្រធានទី២ព្រឹទ្ធសភា ដោយមានសំឡេងគាំទ្រ ចំនួន ៦២សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

សូមបញ្ជាក់ថា ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភានីតិកាលទី៤ ទាំង៦២រូប នឹងអញ្ជើញធ្វើសច្ចាប្រណិធាននៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ និងទេវតារក្សាស្វេតច្ឆត្រ នារសៀលថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ វេលាម៉ោង ១៦:០០នាទី នៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃចន្ទ ៩កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨

**អគ្គលេខាធិការ**

អ៊ុំ សារឹទ្ធ